# កាលប្បវត្តិ
## ស្តីពីការកើតឡើង និងធ្លាក់ចុះនៃអំណាចរបស់របបខ្មែរក្រហម

*ប្រែសម្រួលដោយ គ្រី ស៊ុយហៀង កែសម្រួលដោយ ញាណ សុជាតិ*

**ទសវត្សរ៍៤០**

ចលនាកុម្មុយនីស្តកម្ពុជា បានកើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង ។

**ទសវត្សរ៍៦០**

សម្តេចព្រះនរោត្តម សីហនុ បានហៅឈ្មោះក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គថា "ខ្មែរក្រហម" ។ ឈ្មោះជាផ្លូវការរបស់ក្រុមនេះគឺ "បក្សកុម្មុយនីស្តកម្ពុជា" ។

**ឆ្នាំ១៩៦៣**

ប៉ុល ពត បានក្លាយទៅជាលេខាបក្ស និងជាមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា ។

**ខែមីនា ឆ្នាំ ១៩៧០**

ការកើតឡើងនៃសង្គ្រាមស៊ីវិលនៅកម្ពុជា ។ លោកសេនាប្រមុខ លន់ នល់ និងសហការីរបស់គាត់ដែលនិយមអាមេរិកបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមសីហនុចេញពីព្រះប្រមុខរដ្ឋដោយជោគជ័យ ។

**ឆ្នាំ១៩៧៣**

ខ្មែរក្រហមបានក្លាយទៅជាអ្នកដើរតួដ៏សំខាន់បំផុតមួយនៅក្នុងសង្គ្រាមស៊ីវិល ហើយសមាជិកភាពរបស់ខ្លួនក៏កើនឡើងដែរ ដោយសារតែមានប្រជាជនជាច្រើនបានខឹងសម្បានឹងរបប លន់ នល់ ។ នៅពេលនេះផងដែរ ប៉ែតសិបប្រាំភាគរយនៃទឹកដីប្រទេសកម្ពុជាត្រូវបានធ្លាក់ក្រោមការត្រួតត្រារបស់ខ្មែរក្រហម ។

**ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង ។ ប៉ុន្មានថ្ងៃបន្ទាប់មក ខ្មែរក្រហមបានបង្ខំប្រជាជនប្រហែលជាជាងពីរលាននាក់ ដែលរស់នៅទីក្រុងភ្នំពេញនិងបណ្តាទីប្រជុំជនផ្សេងៗទៀត ឲ្យចេញទៅរស់នៅទីជនបទដើម្បីធ្វើការងារស្រែចម្ការ ។ នៅពេលជម្លៀសនោះ គឺមានប្រជាជនរាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិត ។ ដោយសារ

តែបែបនេះហើយ គួបផ្សំនឹងគោលនយោបាយផ្សេងៗទៀតនោះ ទើបធ្វើឲ្យប្រជាជនជាង ពីរលាននាក់បាន ស្លាប់ក្នុងអំឡុងរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។

## ឆ្នាំ១៩៧៦

បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតនូវរដ្ឋកម្ពុជាប្រជាធិបតេយ្យ ហើយបានសរសេរនូវគម្រោងលើកទីមួយរបស់ខ្លួនគឺ «ផែនការបួនឆ្នាំ» ដែលតម្រូវឲ្យមានការប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់ដាក់ជារួម និងផ្តល់អតិភាពចម្បងបំផុតរបស់ជាតិទៅលើការដាំដុះស្រូវ ។ ប្រជាជនកម្ពុជាគ្រប់រូបត្រូវបានតម្រូវឲ្យប្រមូលកម្មសិទ្ធឯកជនទាំងអស់របស់ខ្លួនដើម្បីដាក់ប្រើប្រាស់ជារួម ។ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ហើយប្រជាជនទាំងអស់ត្រូវបានដាក់ឲ្យធ្វើការងារជាក្រុម ។ គោលបំណងរបស់គម្រោងផែនការបួនឆ្នាំ គឺដើម្បីសម្រេចឲ្យបាននូវផលិតផលសម្រាប់ជាតិជាមធ្យមចំនួនបីតោនក្នុងមួយហិកតារ ។ ដើម្បីសម្រេចនូវគោលបំណងនេះ ប្រជាជនកម្ពុជាភាគច្រើនត្រូវបានបង្ខំឲ្យធ្វើការដាំដុះប្រូតកាត់ស្រូវរយៈពេលដប់ពីរម៉ោងក្នុងមួយថ្ងៃ ដោយមិនបានសម្រាក ឬក៏ទទួលទានអាហារឲ្យបានគ្រប់គ្រាន់ទេ ។

## ចុងឆ្នាំ១៩៧៧

ជម្លោះបានផ្ទុះឡើងរវាងប្រទេសកម្ពុជា និងវៀតណាម ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានបញ្ជូនទៅច្បាំង ហើយរាប់ពាន់នាក់បានស្លាប់ ។

## ខែធ្នូ ឆ្នាំ១៩៧៨

កងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយសម្រុកចូលប្រទេសកម្ពុជា ។

## ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

កងទ័ពវៀតណាមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ។ មេដឹកនាំខ្មែរក្រហមបានរត់ភៀសខ្លួនទៅខាងលិចប្រទេស ហើយបានរៀបចំស្តារកម្លាំងរបស់ខ្លួនឡើងវិញនៅក្នុងទឹកដីថៃ ។

## ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩០

អង្គការសហប្រជាជាតិទទួលស្គាល់រដ្ឋាភិបាលខ្មែរក្រហមថា ជាតំណាងស្របច្បាប់តែមួយគត់របស់កម្ពុជា ។

## ឆ្នាំ១៩៨២

ខ្មែរក្រហមបានបង្កើតនូវរដ្ឋាភិបាលចម្រុះត្រីភាគី ។ នៅភ្នំពេញឯណោះវិញ វៀតណាមបានជួយបង្កើតរដ្ឋាភិបាលថ្មីមួយគឺ "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ដែលបានដឹកនាំប្រទេសកម្ពុជា អស់រយៈពេលមួយទសវត្សរ៍ ។

**ឆ្នាំ១៩៩០**

កងទ័ពវៀតណាមបានដកថយចេញពីប្រទេសកម្ពុជា ។

## ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

រាល់ភាគីជម្លោះកម្ពុជាទាំងអស់ បានយល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ហើយបានយល់ព្រមឲ្យមានការរៀបចំការបោះឆ្នោតជាតិមួយ ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជាហៅកាត់ថា "អ៊ុនតាក់" ។ ក្រុមខ្មែរក្រហមបានធ្វើពហិការមិនចូលរួមការបោះឆ្នោតជាតិដែលរៀបចំឡើងដោយអ៊ុនតាក់ ហើយបដិសេធមិនព្រមរំសាយកងទ័ពរបស់ខ្លួនឡើយ ។

**ឆ្នាំ១៩៩៣**

រដ្ឋាភិបាលថ្មីមួយដែលត្រូវបានហៅថា "រាជរដ្ឋាភិបាលកម្ពុជា" ត្រូវបានបោះឆ្នោតឲ្យឡើងកាន់កាប់អំណាច ។ កងទ័ពខ្មែរក្រហមបានបន្តវាយប្រយុទ្ធប្រឆាំងនឹងកងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំបន្តទៀត ។

**ឆ្នាំ១៩៩៨**

ប៉ុល ពត បានស្លាប់ ។ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ផ្សេងៗបានចុះចូលនៅឆ្នាំ១៩៩៨ ។

**ខែមីនា ឆ្នាំ១៩៩៩**

តា ម៉ុក ដែលជាមេដឹកនាំខ្មែរក្រហមតែម្នាក់គត់ដែលបដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាត្រូវបានចាប់ខ្លួន ។

**ឆ្នាំ១៩៩៩**

ចលនាខ្មែរក្រហមបានដួលរលំទាំងស្រុង ។ មេដឹកនាំខ្មែរក្រហមទាំងអស់ ខ្លះបានចុះចូលនឹងរាជរដ្ឋាភិបាលកម្ពុជា ខ្លះទៀតត្រូវបានចាប់ខ្លួនឬក៏ស្លាប់ ។